# មេរៀនទី៧១៖ ព្រះយេស៊ូវមានព្រះជន្មរស់ឡើងវិញ!

[ម៉ាកុស ១៦៖ ១- ៨]

**មេរៀនសម្រាប់គ្រូ** ( *យូធូបលីង* )៖ https://youtu.be/aj1bT040CNs

**រឿងនៅក្នុងព្រះគម្ពីរសម្រាប់កុមារ៖** https://youtu.be/7pc8HXTadYI

**ខគម្ពីរចងចាំ៖ យ៉ូហាន ១១៖២៥** *ព្រះយេស៊ូវមានព្រះបន្ទូលទៅនាងថា ខ្ញុំជាសេចក្តីរស់ឡើងវិញ ហើយជាជីវិត អ្នកណាដែលជឿដល់ខ្ញុំ ទោះបើបានស្លាប់ហើយគង់តែនឹងរស់ឡើងវិញដែរ”។*

**ចំរៀង** ( *យូធូបលីង* )៖

១.នៅរស់ https://youtu.be/NGQXTg3Uogg

២. ព្រះគ្រីស្ទទ្រង់រស់ https://youtu.be/kzg10u5bil4

៣. ទ្រង់រស់សព្វថ្ងៃ https://youtu.be/Ux9ClfRcNSw

## ១. អធិស្ឋាន

## ២. ចំរៀង ( *រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស* )

## ៣. ល្បែងកំសាន្ត «ឋានសួគ៌នឹងនិងឋាននរក»

១. ចែកកុមារជា២ឬ៣ក្រុមហើយក្រុមនីមួយៗត្រូវឈរជាជួរ។

២. នៅពេលដែលគ្រូ ស្រែកថា “ឋានសួគ៌” កុមារត្រូវលោតទៅខាងស្តាំ ហើយនៅពេលដែលគ្រូស្រែកថា “ឋាននរក” កុមារត្រូវលោតទៅខាងឆ្វេង។

៣.ប្រសិនបើគ្រូនៅស្រែកថា “ឋានសួគ៌” កុមារត្រូវតែបន្តលោតទៅខាងស្តាំដដែល។ ពេលខ្លះគ្រូព្យាយាម លោតបន្លំកុមារឲ្យខុសពីអ្វី ដែលគាត់បានស្រែក ដើម្បីឲ្យកុមារធ្វើខុសតាមគាត់។

៤. បន្ទាប់ពីលេងល្បែងនេះចប់ គ្រូសូមពន្យល់កុមារថា ព្រះយេស៊ូវបានសុគតសម្រាប់យើង ដូច្នេះយើងមិនត្រូវទៅឋាននរកនោះទេ។ ហើយជំនួសឲ្យការធ្លាក់ទៅឋាននរកពួកយើងបានទៅឯនគរឋានសួគ៌ជាមួយព្រះយេស៊ូវជារៀងរហូត ពីព្រោះព្រះយេស៊ូវបានរស់ពីសុគតឡើងវិញ។ ព្រះយេស៊ូវមានព្រះជន្មរស់!

## ៤. ការណែនាំមេរៀន

នៅថ្ងៃសុក្រដ៏ល្អកាលពី២០០០ឆ្នាំមុន ព្រះយេស៊ូវគ្រីស្ទ ជាព្រះអង្គសង្គ្រោះរបស់យើង ត្រូវបានសុគតដោយការឆ្កាង។ វាជាការសុគតដ៏ឈឺចាប់ និងឃោរឃៅដែលធ្វើឲ្យយើងភ័យខ្លាចនៅថ្ងៃនេះ - ជាពិសេសនៅពេលយើងដឹងថាព្រះគ្រីស្ទបានសុគតជំនួសយើង។ គឺយើងទេដែលត្រូវស្លាប់ តែព្រះយេស៊ូវជាអ្នកសុគតជំនួស។ ប៉ុន្តែនៅថ្ងៃទីបី ព្រះគ្រីស្ទបានមានព្រះជន្មរស់ឡើងវិញ ទ្រង់មានជ័យជម្នះ ហើយឈ្នះលើសេចក្តីស្លាប់! តាមរយៈការសុគតរបស់ទ្រង់ ព្រះអង្គបានប្រោសលោះយើងរួចពីអំពើបាប របស់យើង។ តាមរយៈការមានព្រះជន្មរស់ឡើងវិញ ព្រះអង្គបង្ហាញពីអំណាចរបស់ទ្រង់ដើម្បីសង្គ្រោះ យើងរួចពីសេចក្តីស្លាប់។ ថ្ងៃនេះ យើងនឹងរៀនអំពីរបៀបដែលយើងអាចរស់នៅជាមួយទ្រង់អស់កល្បជានិច្ច ដោយសារការសុគត និងការរស់ឡើងវិញរបស់ព្រះគ្រីស្ទ។

## ៥. រឿងនៅក្នុងព្រះគម្ពីរ

ពេលយើងធ្វើបាប ទោសនៃអំពើបាបនោះគឺជាសេចក្តីស្លាប់។ ដោយសារយើងទាំងអស់គ្នាបាន ប្រព្រឹត្តអំពើបាប យើងទាំងអស់គ្នាសមនឹងត្រូវស្លាប់។ ប៉ុន្តែ ព្រះយេស៊ូវមិនចង់ឲ្យយើងត្រូវស្លាប់ដោយសារ អំពើបាបរបស់យើងទេ។ ព្រះយេស៊ូវបានសុគតដើម្បីទទួលទោសចំពោះអំពើបាបដែលយើងបានប្រព្រឹត្ត។ ទ្រង់បានសុគតនៅលើឈើឆ្កាងសម្រាប់អំពើបាបរបស់យើង!

ព្រះគម្ពីរប្រាប់យើងថា ស្ត្រីទាំងនោះបានទៅផ្នូរនៅថ្ងៃទីបី បន្ទាប់ពីព្រះយេស៊ូវបានសុគតនៅលើឈើឆ្កាង។ ពួកគេភ្ញាក់ផ្អើលដែលបានឃើញផ្នូរនៅទទេ! បន្ទាប់មក ទេវតាមួយអង្គបានប្រាប់ពួកគេថា ព្រះយេស៊ូវមានព្រះជន្មរស់ឡើងវិញហើយ។ ម៉ារាភ័យខ្លាចហើយមិនហ៊ានប្រាប់អ្នកណាឡើយ រហូតដល់ព្រះយេស៊ូវបានលេចមកឲ្យនាងឃើញ។ បន្ទាប់មកនាងបានប្រាប់ពួកសិស្ស ប៉ុន្តែមានអ្នកខ្លះមិនជឿនាងទេ រហូតដល់ព្រះយេស៊ូវបានបង្ហាញខ្លួនចំពោះមុខពួកគេ។ ពេលសិស្សរបស់ទ្រង់បានឃើញថា ព្រះយេស៊ូវមានព្រះជន្មរស់ឡើងវិញ ខ្លះរំភើប ខ្លះរីករាយ ខ្លះភ័យខ្លាច និងខ្លះមានអារម្មណ៍ច្របូកច្របល់។

មុនពេលព្រះយេស៊ូវសុគត ព្រះអង្គបានប្រាប់ពួកសិស្សថា ព្រះអង្គនឹងសុគត ហើយនៅថ្ងៃទីបីទ្រង់នឹងមានព្រះជន្មរស់ឡើងវិញ។ ទោះជាយ៉ាងណា ពួកសិស្សហាក់មិនទាន់យល់ទាំងស្រុងនៅឡើយទេ។ ពួកគេនៅមាន ការច្របូកច្របល់បន្តិចចំពោះអ្វីដែលព្រះយេស៊ូវបានមានបន្ទូល។ ប៉ុន្តែ យើងមិនត្រូវមានការភ័ន្តច្រឡំទេ ព្រោះយើងមានព្រះគម្ពីរទាំងមូលសម្រាប់អាន។ ព្រះគម្ពីរប្រាប់យើងយ៉ាងច្បាស់ថា ព្រះយេស៊ូវនឹងសុគត ហើយមានព្រះជន្មរស់ឡើងវិញ។ ហើយនោះជាអ្វីដែលបានកើតឡើង។

ព្រះយេស៊ូវមានព្រះជន្មរស់ឡើងវិញ ដើម្បីបង្ហាញគ្រប់គ្នាថា ទ្រង់ជាព្រះដ៏មានឫទ្ធានុភាព និងសិរីរុងរឿងរបស់យើង។ គ្មានអ្វីមានអំណាចជាងព្រះយេស៊ូវឡើយ! ដោយសារព្រះយេស៊ូវបានសុគត ហើយមានព្រះជន្មរស់ឡើងវិញ ទើបអំពើបាបរបស់យើងអាចត្រូវបានលើកលែងទោសឲ្យ។ យើងអាចរស់នៅជាមួយព្រះយេស៊ូវអស់កល្បជានិច្ចនៅឯនគរស្ថានសួគ៌។

ហើយទ្រង់ប្រទានសេចក្តីសង្គ្រោះដល់យើងជាអំណោយឥតគិតថ្លៃ។ យើងមិនចាំបាច់ចំណាយអ្វីសម្រាប់ការសង្គ្រោះនោះទេ។ យើងគ្រាន់តែជឿលើព្រះយេស៊ូវ ហើយទទួលយកអំណោយនៃសេចក្តីសង្គ្រោះរបស់ទ្រង់។ ក្រោយពីទ្រង់មានព្រះជន្មរស់ឡើងវិញ ព្រះយេស៊ូវបានបង្ហាញខ្លួនដល់មនុស្ស ដើម្បីឲ្យគេដឹងថាព្រះអង្គនៅមានព្រះជន្មរស់។ ព្រះអង្គស្រឡាញ់ពួកគេខ្លាំងណាស់ ហើយទ្រង់ចង់ឱ្យពួកគេជឿលើព្រះអង្គ។

ព្រះយេស៊ូវស្រឡាញ់អ្នកខ្លាំងណាស់។ ទ្រង់ចង់ឱ្យអ្នកជឿលើព្រះអង្គផងដែរ។ ដោយជឿថាព្រះយេស៊ូវជាស្តេចរបស់យើងមានព្រះជន្មរស់នៅសព្វថ្ងៃនេះ!

## ៦. សំនួរពិភាក្សា

១. តើអ្វីជាការដាក់ទោសសំរាប់អំពើបាប? *(សេចក្តីស្លាប់)*

២. តើអ្នកណាបានស្លាប់សំរាប់អំពើបាបយើង? *(ព្រះយេស៊ូវ)*

៣.តើមានអ្វីកើតឡើង បន្ទាប់ពីព្រះយេស៊ូវបានសុគតនៅលើឈើឆ្កាង? *(ព្រះយេស៊ូវមានព្រះ ជន្មរស់ឡើងវិញ)*

៤.តើយើងទទួលបានសេចក្តីសង្គ្រោះតាមរយៈអំណាចរបស់ព្រះយេស៊ូវដោយរបៀបណា? *(ដោយការជឿថាព្រះយេស៊ូវបានសុគតសំរាប់អំពើបាបយើង ហើយទ្រង់មានព្រះជន្មរស់ឡើងវិញដើម្បីសង្គ្រោះយើង)*

៥. តើអ្នកបានសង្គ្រោះដែរឬទេ? *(សូមឲ្យកុមារឆ្លើយ)*

**៧. ល្បែងកំសាន្ត** **«ដណ្តើមដបទឹក»**

១. ឲ្យកុមារចាប់ដៃគូរ២នាក់ៗ

២. ចែកដបទឹកឲ្យក្រុមនីមួយៗ

៣ ឲ្យក្រុមនីមួយៗឈរជាជួរទល់មុខគ្នា ហើយដាក់ដបទឹកនៅចំកណ្តាល។

៤. នៅពេលដែលគ្រូស្រែកថា "១ ២ ៣ ទៅ!" ពួកគេត្រូវរត់ទៅដណ្តើមដបទឹកពីដៃគូរបស់ពួកគេ។

៥. អ្នកដែលអាចដណ្តើមដបទឹកបានមុនគេ គឺជាអ្នកឈ្នះ។

៦. នៅពេលលេងល្បែងនេះចប់សូមពន្យល់កុមារថា ជីវិតរបស់យើងប្រៀបបីដូចជាដបទឹកអីចឹង សាតាំងតែងតែព្យាយាមឆក់យកយើងពីព្រះ។ ប៉ុន្តែព្រះយេស៊ូវបានសុគតដើម្បីលោះយើងពីអំពើបាបនិងសេចក្តីស្លាប់ ដូច្នេះ យើងអាចរស់នៅជាមួយទ្រង់នៅឯនគរស្ថានសួគ៌អស់កល្បជានិច្ច គឺដល់អស់អ្នកដែលជឿដល់ព្រះនាមទ្រង់។

**៨. ខគម្ពីរចងចាំ**

**យ៉ូហាន ១១:២៥** *"ព្រះយេស៊ូវមានព្រះបន្ទូលទៅនាងថា ខ្ញុំជាសេចក្តីរស់ឡើងវិញ ហើយជាជីវិត អ្នកណាដែលជឿដល់ខ្ញុំ ទោះបើបានស្លាប់ហើយគង់តែនឹងរស់ឡើងវិញដែរ"។*

**៩. ហត្ថកម្ម**

**សម្ភារៈដែលត្រូវការ៖** បោះពុម្ពឯកសារទំព័រខាងក្រោម ខ្មៅដៃពណ៌ និងកន្ត្រៃ




១. បោះពុម្ព និងចែកឲ្យកុមារម្នាក់១សន្លឹក។

២. កុមារគួរកាត់ចេញជារាង៣ ហើយផាត់ពណ៌ និងគូរជារង្វង់លើរូបដែលមានព្រះយេស៊ូវ។

៣.យករូបព្រះយេស៊ូវដែលបានកាត់ហើយនោះ ទៅបិទពីក្រោយរូបផ្នូរ។

៤. យករូបដុំថ្មទៅបិទខាងលើ ឬចំហៀងរូបផ្នូរដើម្បីបង្ហាញថាផ្នូររបើក ដែលមានរូបព្រះយេស៊ូវមានព្រះជន្មរស់ឡើងវិញនៅខាងក្នុង (អាចប្រើម្ជុលសម្រាប់ដេរខោអាវមកដេរភ្ជាប់ក៏បាន)។

**១០. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

**១១. អធិស្ឋាន**

**ការថ្វាយបង្គំសំរាប់គ្រូ៖ (សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន)**
យើងមិនបំរើអ្នកដឹកនាំដែលបានស្លាប់ហើយដូចសាសនាផ្សេងៗនោះទេ។ ព្រះយេស៊ូវមានព្រះជន្មរស់ឡើងវិញ! ដោយសារទ្រង់រស់ យើងគ្រប់គ្នាអាចធ្វើឲ្យទំនាក់ទំនងយើងរីកចំរើន និងមានមិតត្ភាពល្អជាមួយនឹងព្រះ! សូមពិចារណាថា តើអ្នកអាចនឹងអរព្រះគុណទ្រង់សំរាប់អំណោយដែលមិនអាចពិព៌ណនាបាន និងអំណាចនៃការមានព្រះជន្មរស់ឡើងវិញដោយរបៀបណា? សូមធ្វើឲ្យថ្ងៃនៃបុណ្យព្រះអង្គមានព្រះជន្មរស់ជាថ្ងៃដ៏ពិសេស។ សូមយកចិត្តទុកដាក់ចំពោះអំណោយដ៏ពិតសំរាប់បុណ្យព្រះអង្គមានព្រះជន្មរស់ឡើងវិញ៖ ជីវិតថ្មីតាមរយៈការសុគត និងមានព្រះជន្មរស់ឡើងវិញរបស់ព្រះយេស៊ូវ។ ហើយសុំកុំឲ្យយើងមានការខ្មាសអៀនក្នុងការប្រាប់អ្នកដទៃថា"ទ្រង់មានព្រះជន្មរស់ឡើង វិញ!"

# ព្រះយេស៊ូវមានព្រះជន្មរស់ឡើងវិញ!







